កម្មវិធីសិលា

# ឯកសារបច្ចេកទេស

# ការចិញ្ចឹមគោ និង រុក្ខជាតិចំណីសត្វ









រៀបចំដោយ ក្រុមគាំទ្របច្ចេកទេសថ្នាក់ខេត្ត ផ្នែកផលិតកម្ម និង បសុព្យាបាល

គំរោង អាដេស ខេត្តបាត់ដំបង ខែ ឧសភា ឆ្នាំ ២០០៤

# មាតិកា

**ចំណងជើង** **ទំព័រ**

I.គោលបំណង នៃវគ្គបណ្តុះបណ្តាល....3

II.គោលបំណង នៃការចិញ្ចឹមគោ....3

III. ការគ្រប់គ្រងសំខាន់ៗ ក្នុងការចិញ្ចឹមគោ....3

៣,១,ជំរក រឺ ក្រោល....3

៣,២,ការជ្រើសរើស ពូជ....4

ក, ការជ្រើសរើសគោឈ្មោល....4

ខ, ការជ្រើសរើសគោមេ....5

គ, សញ្ញានៃការរកឈ្មោល....5

ឃ, របៀបបង្កាត់ពូជ....6

ង, ការប៉ាន់ស្មាន អាយុគោ ដោយសង្កេត លើ បន្ទាស់ធ្មេញ របស់វា....6

៣,៣,ចំណី និង ការផ្តល់ចំណី....8

ក, ការចិញ្ចឹមគោឈ្មោល....8

ខ, ការចិញ្ចឹមគោ ញី....8

៣,៤,វិធានការណ៍ ការពារ និង អនាម័យ....9

ក, តារាង ពេលវេលាដែលត្រូវចាក់វ៉ាក់សាំង ការពារជំងឺ គោ ក្របី....10

V. ដំណាំ ចំណី សត្វ....10

១, និយមន័យ រុក្ខជាតិចំណីសត្វ....10

២, ប្រភេទ....11

២,១, ប្រភេទដើមឈើ....11

២,២, ដើមកន្ទំថេត....11

២,៣, ស្មៅគោគ....13

២,៤, ស្មៅដីរ....15

VI. តារាងតាមដាន ការចិញ្ចឹមគោ-ក្របី....16

## I. គោលបំណង នៃវគ្គបណ្តុះបណ្តាល

ក្រោយបញ្ចប់វគ្គសិក្សានេះ កសិករ និង :

១. ចេះកែលំអ ការចិញ្ចឹមគោ ជាលក្ខណះសាមញ្ញ អោយសមស្របទៅតាមបច្ចេកទេស និង ទទួលបានជោគជ័យ ដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសារ ។

២. ស្គាល់ និង ចេះប្រើប្រាស់រុក្ខជាតិ ចំណីសត្វ ( កន្ទំថេត,ស្មៅគោគ, ស្មៅដីរ៉ ) ។

## II. គោលបំណង នៃការចិញ្ចឹមគោ

- ផ្តល់ជាកំលាំងអូសទាញ សំរាប់ការងារកសិកម្ម
- ផ្តល់ជាសាច់ និង ទឹកដោះ សំរាប់មនុស្សបរិភោគ
- ផ្តល់ការផលិតកូន សំរាប់បន្តពូជ
- ផ្តល់ស្បែក សំរាប់ធ្វើ ឧបករណ៍ប្រើប្រាស់ច្រើនប្រភេទ
- ផ្តល់លាមកសំរាប់ធ្វើ ជី បង្កើនផលិតផលកសិកម្ម

## III. ការគ្រប់គ្រង សំខាន់ៗ ក្នុងការចិញ្ចឹមគោ

- ជំរក រឺ ក្រោល
- ការជ្រើសរើសពូជគោ
- ការផ្តល់ចំណីអាហារ ការថែទាំ និង ការការពារ

### ៣,១. ជំរក រឺ ក្រោល

គោ ក្របី ត្រូវការចាំបាច់ នូវជំរក ដើម្បីការពារនូវកំដៅព្រះអាទិត្យ ការពារនៅរដូវវស្សា ពេលមាន ភ្លៀងធ្លាក់ខ្លាំងដូចមនុស្សយើងដែរ ប៉ុន្តែជំរកមិនចាំបាច់មានជញ្ជាំងសងខាងទេ ដើម្បីទុកអោយខ្យល់ចេញចូលក្នុងជំរកគោអោយ បានល្អ ។ ត្រូវសង់ជំរកគោនៅលើដីទួល កន្លែងដេកនៅរបស់វាត្រូវអោយស្ងួតហើយស្អាតជានិច្ច ពីព្រោះមេរោគទាំងឡាយ ចូលចិត្តរស់នៅ ក្នុងលាមកភក់ជ្រាំណាស់ ។ ប្រជាកសិករខ្លះមានផ្ទះធំខ្ពស់ផុតពីដី ដែលអាចធ្វើជាជំរកគោបាននៅខាងក្រោមផ្ទះ តែមិនសូវល្អដូចជាសាងសង់រោង សំរាប់ជាជំរកវា ដាច់ដោយឡែក ទេ។

ដើម្បីរក្សាទុកលាមកគោ ក្របី សំរាប់ធ្វើជី ចាំបាច់ត្រូវជីករណ្តៅ ធំមួយមានប្រក់ដំបូល ការពារពន្លឺថ្ងៃ និងភ្លៀង ។ រណ្តៅធ្វើទៅតាមលទ្ធភាពរបស់កសិករដែលអាចធ្វើបាន បើសិនពុំមានការប្រមូលទុកដាក់ក្នុងរណ្តៅទេ លាមកដែលត្រូវទុកធ្វើជីនោះ ត្រូវភ្លៀង រឺខ្យល់ អាចធ្វើអោយហួតបាត់បង់នូវគុណភាព របស់វានៅពេល ដែលយើង យកទៅប្រើប្រាស់ ។

## ៣,២,ការជ្រើសរើសពូជ

ពូជជាកត្តាសំខាន់ បំផុតក្នុងការចិញ្ចឹម ដូច្នេះយើងត្រូវដឹង អំពី ពូជ និង ប្រវត្តិ ច្បាស់លាស់ ។ នៅប្រទេសកម្ពុជាយើងនាពេលបច្ចុប្បន្ន យើងឃើញមានពូជ គោ បរទេស និង ពូជក្នុងស្រុក ។ ហើយប្រជាកសិករភាគ ច្រើននិយមចិញ្ចឹមគោកូនកាត់ រវាងពូជបរទេស និង ពូជក្នុងស្រុក ។

### ក, ការជ្រើសរើសគោឈ្មោល :

អំពីរូបរាង : មាឌធំ មានលំនិង ខ្ពស់មុខទាបក្រោយ រហ័សរហួន ស្លូត ។

ផ្នែកដ៏ទៃទៀត :

- ក្បាលធំល្មម តែវែង ថ្ងាស ទូលាយ មាត់ទូលាយ ច្រមុះសើម ស្លឹកត្រចៀក ធំល្មម ធ្មេញស ស្មើជិតគ្នាគ្មានប្រេះស្រាំ ស្នែងស្មើ ។
- ក និង ដងខ្លួន : កវែងល្មម ទ្រូងទូលាយ ស្មាទូលាយ ខ្នងវែង ត្រង់ រឹកោង លេច ឡើង លើបន្តិច ឆ្អឹងជំនី ធំមូល ឆ្អឹងត្រគាគធំទូលាយ ។
- ជើង : ជើងទាំងបួនធំត្រង់ ជើងមុខទាំងពីរឃ្លាតគ្នាត្រង់ បាតជើង ត្រង់ខ្លី ធំល្មម ក្បាលជង្គង់មូល ភ្លៅក្រោយទាំងពីរ ធំវែង ក្រចកជើងជិតរឹងមាំ ។
- កន្ទុយ : ធំ
- ស្បែក : រលោងស្តើងល្មម រោមរាប ជាប់ស្បែក ។
- ប្រដាប់បន្តពូជ : ពងទាំង ពីរធំស្មើ ។
- លទ្ធភាពធ្វើការងារ : ដើរមិនទង្គិចជង្គង់ មិនក្បៀសក្រចក បាតជើងក្រោយ ទាំងពីរ ដើរ ចំបាតជើងមុខ រឺ ក៏ហួសទៅមុខបន្តិច ។ សាកល្បងយកវាទៅភ្ជួររាស់ អូសរទេះ រើសទុកតែ គោណាដែលដើរលឿន មិនងាយហាត់ ។

រូបភាព ពូជគោ បរទេស និង កូនកាត់

**ខ,ការជ្រើសរើស គោមេ :**

- មានរូបរាងស្អាត សុខភាពល្អ
- ក្រសោមដោះធំ សរសៃឈាមលើដោះ លេចចេញច្បាស់ ក្បាលដោះធំស្មើ ខ្លាតពីគ្នា រោមទន់ យោនីរីកស្មើ ។
- ត្រគាគ រីកធំ

<u>រូបភាពគោញី</u>

**គ,សញ្ញានៃការរកឈ្មោល :** ចំពោះគោ ញី ចាប់ផ្តើមរកឈ្មោល កើលដំបូង ក្នុងអាយុ ១៨-២៤ ខែ ។ គោ និង រកឈ្មោល រៀងរាល់ ២១ថ្ងៃ ។ សញ្ញានៃការរកឈ្មោលខ្លះដូចជា :

- មិនសូវស៊ីស្មៅទេ
- ចេះតែស្រែករោទ៍ មានភាពរសាប់រសល់ ច្រាសច្រាល ឡើងពាក់គោ ដ៏ទៃដែល នៅជិតខ្លួន ។
- ប្រដាប់បន្តពូជរបស់វារីកធំ មានពណ៌ក្រហមព្រៀង១រលោង និងមានហូរ ទឹករំអិលតិច១សរថ្លា ។
- ពេលជួបបាម្តង១វាត្រៀមខ្លួនអោយបាពាក់ ជួនឡើងពាក់បាមុនក៏មាន ។បើនៅក្នុងហ្វូងវាឡើងពាក់គេឯងដែលនៅជិតវា ។

ជួនកាលមេគោ បង្ហាញអោយឃើញ នូវសញ្ញាទាំងនេះ ប៉ុន្តែជួនកាលទៀត វាក៏បង្ហាញតែសញ្ញាខ្លះ១ប៉ុណ្ណោះ និង គោខ្លះទៀតបង្ហាញនូវសញ្ញានេះតិចតួច ណាស់ ហើយរយះពេលខ្លីរី ក៏គ្មានតែម្តង ចំពោះការរកឈ្មោល ។ រយះពេលផើម ៩ ខែ ១០ ថ្ងៃ (២៨០-២៨៥ថ្ងៃ) ។

បញ្ជាក់ : រយះពេល កំពង់រកឈ្មោល មានរយះពេល ៣ថ្ងៃ ។ ចំពោះមេគោ រកឈ្មោលលើកទី ១ មិនត្រូវដាក់ ឈ្មោលទេ ចាំលើកទី ២ ទើបដាក់ ទៅទើបបានទទួលលទ្ធផលល្អ ។

រូបភាព សញ្ញានៃការរកឈ្មោល

**ឃ,របៀបបង្កាត់ពូជ** : ត្រូវជ្រើសរើស រកបាណាដែលមានប្រវត្តិពូជល្អ ដែលក្នុងភូមិ រឺក្នុង ឃុំ យើងមាន កាលណាមេគោ រកឈ្មោល យើងត្រូវ យកបាណាដែលយើងពេញចិត្ត នៅក្នុងតំបន់ ជិតនោះមាន ទើបធ្វើ អោយការបង្កាត់ពូជ ទទួលបានលទ្ធផល និង ធានាការអូសទាញ ។

បញ្ជាក់ :ត្រូវចៀសវាងកុំយកមេគោ ពូជក្នុងស្រុកបង្កាត់ជាមួយបានាំចូលពីបរទេស ផលវិបាក នាំអោយកូន កើតមិនរួច ។

## ខ,ការប៉ាន់ស្មាន អាយុគោ ដោយសង្កេតលើ បន្លាស់ធ្មេញរបស់វា

យើងអាចប៉ាន់ស្មានអាយុរបស់គោបានច្បាស់ នៅពេលវាមានអាយុ ១៨ ខែឡើងទៅ ដោយសំគាល់តាម រយះការ ផ្លាស់ប្តូរធ្មេញរបស់វា ដែលមានចំនួន ៨ នៅផ្នែកខាងមុខ និង ជួរខាងក្រោម ។ គោមានធ្មេញពីរប្រភេទ គឺ ធ្មេញទឹកដោះ និង ធ្មេញចាស់ ( ធ្មេញបន្លាស់) ។ ធ្មេញចាស់ រឺ ធ្មេញបន្លាស់ ដុះជំនួសធ្មេញទឹកដោះម្តងពីរៗ ផ្តើមចេញ ពីចន្លោះកណ្តាលទៅ ហើយមានទំហំធំជាងធ្មេញទឹកដោះ ។

- អាយុ ១៨ ខែ វាមានធ្មេញចាស់ ២ ដុះនៅចន្លោះកណ្តាល ធ្មេញទឹកដោះ ៦
- អាយុ ២ឆ្នាំ វាមានធ្មេញចាស់ ៤ ដុះនៅចន្លោះកណ្តាល ធ្មេញទឹកដោះ ៤
- អាយុ ៣ ឆ្នាំ វាមាធ្មេញចាស់ ៦ ដុះនៅចន្លោះកណ្តាល ធ្មេញទឹកដោះ ២
- អាយុ ៤ ឆ្នាំ វាមានធ្មេញចាស់ ៨ ។

រូបភាព បន្លាស់ធ្មេញ  និង អាយុរបស់គោ

## ៣,៣,ចំណី និង ការផ្តល់ចំណី :

### ក,ការចិញ្ចឹមគោ ឈ្មោល :

- ការផ្តល់ ចំណី : រដូវរកញី ឈ្មោល ត្រូវបង្កើនចំណី ពី ១០-២០% ក្នុង ១ថ្ងៃ ប្រៀប និងការអោយស៊ីធម្មតា ។ អោយស៊ីបន្ថែម កន្ទក់ ពន្លកស្រូវ រឺ ស្មៅខ្ចី ស្លឹក កន្ទំថេត,ស្លឹកអង្កាញ់, អំបិល (៣គក្រចំបើង +០,៥ គក្រ ពន្លកស្រូវ រឺ ស្មៅខ្ចី + ១,៥០ គក្រ កន្ទក់ម៉ត់ + ៦០ ក្រាម អំបិល ក្នុងគោ ១ក្បាល) ។
- ការថែទាំ : ខែក្តៅត្រូវ ឧស្សាហ៍ លាងទឹក ផ្តល់ទឹកអោយផឹកគ្រប់គ្រាន់ និង លែងអោយ វាដើរស៊ីចំណី ដោយសេរី ។
- ខែភ្លៀង បន្ថយពេលវេលាលែងអោយវាដើរកចំណី ។
- ត្រួតពិនិត្យមើលក្រចកជើង ។
- ចាប់ ពីអាយុ ៨-១០ខែ ត្រូវខ្ទះច្រមុះ ដើម្បីងាយស្រួលដឹកវា ។
- អាចអោយវាពាក់ញី ក្នុងអាយុ ១៨-២៤ ខែ ។ ប្រើប្រាស់មានប្រសិទ្ធិភាពល្អ គឺ ក្នុង ចន្លោះ ពី ២-៦ ឆ្នាំ ។

### ខ,ការចិញ្ចឹមគោ ញី :

១,ការផ្តល់ចំណី : ត្រូវថែទាំមេគោធើម អោយបានហ្មត់ចត់ មិនត្រូវអោយវាធ្វើការហួសកំលាំងទេ រឺ ព្រលែងសត្វអោយរត់ដោយសេរី ជល់គ្នាជៀងវាងការរលូតកូន ។

- ពេលកើតកូនត្រូវ អោយ ស៊ីស្មៅខ្ចី បន្ថែម ,កន្ទក់,ស្លឹកកន្ទំថេត,ស្លឹកអង្កាញ់,អំបិល (៥០ក្រាម ក្នុងគោ ១ក្បាលក្នុង១ថ្ងៃ ) ។

២,ការថែទាំ : មុន ពេលកើត អោយមេគោ សំរាក ពីការងារ ១-២ ខែ មុនពេលកើត ។

- អោយស៊ីស្មៅខ្ចី,ស្លឹកកន្ទំថេត,ស្លឹកអង្កាញ់ ទឹកស្អាតគ្រប់គ្រាន់ ។
- ក្រោលត្រូវស្ងៀមស្ងាត់ ។

៣,សញ្ញា នៃការជិតកើតកូន : ពោះរបស់មេគោ រីកធំ ,ក្បាលដោះរីក ធំ និង មានទឹក ដោះហូរ តិចៗ ចេញ ពីចុងដោះទាំងបួន ,ប្រដាប់បន្តពូជរីកធំ និង មាន ទឹករំអិលហូរចេញ មក ។ ក្នុង លក្ខណះ នេះ មេគោត្រូវសំរាក ហើយយើងត្រូវពិនិត្យមើល អោយបាន ៣-៤ ដង ក្នុង ១ថ្ងៃ ក្រែង មានកើតបញ្ហា

៤,ពេលកើត : ជាទូទៅ ការបង្កើតកូន របស់មេគោ មិនសូវមានបញ្ហាទេ លើកលែងតែក្នុងករណីយ ដែលមេពិបាក កើតដោយសារកូនភ្លោះ រឺ ក៏កូនក្នុងពោះស្ថិតក្នុងសភាព មិនធម្មតា ។ អោយមេគោផឹក ទឹកអំបិល រឺ ក៏ទឹក តែលាយស្រា (ទឹកតែ ១លីត្រ +ស្រា ១០ស្លាបព្រាបាយ) តាមធម្មតាសុក ធ្លាក់អស់

ចន្លោះពេល ពី ៤-៦ ម៉ោង ។

៥.<u>ក្រោយពេលកើត</u> :យកទឹកក្តៅឧណ្ហៗលាយ អំបិលលាងសំអាតដោះ យោនី និង មុំគូថខាងក្រោយ ។

- កើតបាន ១ម៉ោង ត្រូវអោយកូនគោបៅដោះ ។
- អោយមេគោស៊ីស្មៅខ្ចី ស៊ីបបរ រី ចំណីណាដែលស្រួលរំលាយ ។
- អោយមេគោ សំរាក ១ ខែ ក្រោយពេលបង្កើតកូន រួចហើយអោយធ្វើការស្រាលៗ ជាបណ្តើៗ

៦.<u>របៀបថែរក្សាកូនគោទើបកើតភ្លាម</u> : កូនគោដែលទើបកើតមកហើយ ជាដំបូងត្រូវ ពិនិត្យរន្ធច្រមុះ ក្រែងមានស្លេស្មបិតជិត ត្រូវត្បារ និង ជូតអោយបានស្អាតនិង ក្រណាត់ស្បៃ ដែលស្ងួតល្អ ប៉ុន្តែមុន នឹងកាត់ ត្រូវច្បួត ឈាមក្នុងទងផ្ចិតអោយអស់ ហើយត្រូវកាត់ផ្ចិត ចំងាយ ពីពោះ ៤-៦ សម កាត់ ហើយត្រូវលាប ថ្នាំ តាំងតែ អ៊ីយូដ រី ថ្នាំសំលាប់ មេរោគ ដ៏ទៃទៀត ។ បន្ទាប់មកត្រូវថ្លឹងកូនគោ ដើម្បីអោយដឹងថានៅ ពេល កើតវា មានទំងន់ប៉ុន្មាន ។ ក្នុង ពេល ជាមួយគ្នា យើងចាំបាច់ត្រូវអោយកូនគោ បៅ ទឹកដោះដំបូង (ទឹកដោះដំបូងដែលមានគ្រឿង ការពារខ្លួន ច្រើន) ទឹកដោះដំបូងនេះការពារ កូន ប្រឆាំង នឹងជំងឺដែលកើតក្នុងរយះពេល មួយខែ។ ដូច្នេះ ហើយយើងត្រូវបង្ខំកូនគោ អោយបៅភ្លាមក្រោយវាកើត ។

<u>រូបភាព របៀបកាត់ផ្ចិតកូនគោ</u>

### ៣.៤.វិធានការការពារ និង អនាម័យ

បញ្ហាសំខាន់ដេលកសិករ ជួបប្រទះក្នុងការចិញ្ចឹមគោ ក្របី គឺ ជំងឺដែលកើតមានជាញឹកញាប់ចំពោះសត្វ គឺ ជំងឺឆ្លង និង ជំងឺបណ្តាលមកពី ប៉ារ៉ាស៊ីត ។

វិធានការណ៍ បង្ការទល់ និង ប៉ារ៉ាស៊ីត អាចធ្វើតាមរបៀប ២ យ៉ាង :

១.　　សំអាតក្រោលដាក់សត្វ ដើម្បីចៀសវាង កុំអោយសត្វឆ្លងប៉ារ៉ាស៊ីតដែលមាននៅ លើសត្វឈឺ.
លាងសំអាត សត្វល្អិតដែលទំជាប់លើស្បែកសត្វ ។

២.　　ផ្តល់ថ្នាំសំលាប់ប៉ារ៉ាស៊ីតទៅអោយសត្វ( ថ្នាំប្រឆាំង និង ប៉ារ៉ាស៊ីត) អាល់បង់ដាស្សុល Albendazole រឺ Ivomec ។

ជំងឺសំខាន់ៗដែលកើតមាននៅប្រទេសកម្ពុជាយើងមាន : ជំងឺអុតក្តាម,សារទឹក,ឈាមខ្មៅ និង បូសខ្យល់ ។ ដូចច្នេះយើងត្រូវយកចិត្តទុកដាក់ ក្នុងការចាក់ថ្នាំការពារលើជំងឺទាំង បួនប្រភេទនេះអោយបានទៀងទាត់ ពីព្រោះកាលណាមានជំងឺនេះកើតឡើងហើយ ការព្យាបាលច្រើនតែគ្មានប្រសិទ្ធិភាព ។

ម្យ៉ាងទៀតកាលណាអ្នកសង្កេតឃើញសត្វឈឺ ត្រូវចាប់អារម្មណ៍ និងមាន វិធាណការណ៍ ដូចជា :

- បំបែកសត្វឈឺចេញ ពិសត្វជា និង ធ្វើអនាម័យ ទីកន្លែងដែលសត្វរស់នៅ ។
- បង្ខាំងសត្វឈឺទុក ដើម្បីងាយស្រួលក្នុងការព្យាបាល និង ការពារនូវការឆ្លងរាលដាល ។
- សាកសពរបស់សត្វស្លាប់ ត្រូវកប់អោយជ្រៅ រឺ ដុតចោលហាមបរិភោគ ។
-

### ក,តារាង ពេលវេលាដែលត្រូវចាក់វ៉ាក់សាំងការពារ ជំងឺគោ ក្របី

| ជំងឺ/ខែ | មករា | កុម្ភះ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សារទឹក | | → | → | → | | | | | | | | |
| អុតក្តាម | | | | | | | → | | | | | |
| បូសខ្យល់ | → | | | | | | | | | | | |
| ឈាមខ្មៅ | → | | | | | | | | | | | |

## IV.ដំណាំចំណីសត្វ

### ១,និយមន័យ រុក្ខជាតិចំណីសត្វ

- រុក្ខជាតិដែលកសិករអាចដាំបាន　មិនទាមទារបច្ចេកទេសខ្ពស់ក្នុងការធ្វើនិងថែទាំ
- រុក្ខជាតិដែលលូតលាស់ឡើងវិញក្រោយពេលប្រមូលផល ។
- រុក្ខជាតិដែលមិនប៉ះពាល់ដល់ប្រព័ន្ធបរិស្ថានជុំវិញនិងសុខមាលភាពអ្នកប្រើប្រាស់ ។
- រុក្ខជាតិដែលជួយទប់ស្កាត់ឬបន្ថយការហូរច្រោះដី ។
- រុក្ខជាតិដែលជួយបង្កើននិងរក្សាគុណភាពដី ។
- រុក្ខជាតិផ្តល់ពហុប្រយោជន៏ ។

## ២,ប្រភេទ :

**២,១,ប្រភេទដើមឈើ :** ប្រភេទ រុក្ខជាតិដែលប្រើប្រាស់ ធ្វើជាចំណីសត្វបានមាន : ដើមកន្ធំថេត, អង្គារដី,ស្មោគោត, និង ប្រភេទដើមឈើដ៏ទៃទៀត ។

### ២,២,ដើម កន្ធំថេត (Leucaena)

#### ក,ផលប្រយោជន៍

- ជាចំណីសត្វដែលមានគុណភាពខ្ពស់ជាងគេ ក្នុងចំណោមរុក្ខជាតិចំណីសត្វផ្សេងៗទៀត ។
- ដើមកន្ធំថេត អាចដាំតាមព្រំរបង ផ្ទះ រឺ ជាចំការជារបងរស់ និង ដាំតាមជំរាល សំរាប់ទប់ស្កាត់ការហូរច្រោះ
- ស្លឹកកន្ធំថេត អាចប្រើផ្សំសំរាប់ធ្វើជីធម្មជាតិ (កំប៉ុស្តិ) ។ ក្នុងដី ១ហិតា គេអាចប្រើស្លឹកកន្ធំថេតស្ងួត ពី ១,៥ ទៅ ២ តោន ស្មើ និង ជីអ៊ុយរ៉េ ចំនួន ២ បាវ ។
- មានការដុះលូតលាស់ល្អនៅរដូវប្រាំង ។
- មែកកន្ធំថេតប្រើប្រាស់ ជាឧសសំរាប់ដុត ។

**ខ,ការជ្រើសរើស ទីតាំងថ្នាល :**

ថ្នាលត្រូវជ្រើសរើសទីតាំងជិតផ្ទះងាយស្រួលស្រោចទឹក និង ពិនិត្យមើលថ្នាល បណ្តុះ ត្រូវការពារសត្វ ពាហនះ រួមទាំងមាន់ ទា ដូច្នេះត្រូវធ្វើរបងបិតជិតជុំវិញជាការល្អ ។

**គ,ការរៀបចំថ្នាល បណ្តុះ :** ត្រូវរៀបចំបណ្តុះកូនកន្ធំថេតអោយបាន ៣-៤ ខែ មុនរដូវវស្សា រឺ មុន ពេល ដក ដាំ ។ ទីថ្នាលបណ្តុះត្រូវ ជីកដីចេញអោយបានចំរៅ 0,៥0 ម ហើយបំបែកដីអោយបានហ្មត់រួចលាយ លាមកសត្វ ជីកំប៉ុស្ត ផេះ អង្កាម បើអាចរកបាន ហើយយកដាក់បាតរណ្តៅថ្នាលដើម្បីធានាអោយគ្រាប់ដុះបានល្អ

រូបភាព ថ្នាលបណ្តុះកូនកន្ធំថេត ទំហំ ២ ម៉ែត្រ x ៤ ម៉ែត្រ និង ការដាំ

**ឃ,ប្រព្រឹត្តិកម្មគ្រាប់ពូជ** ( ការសំរួលដំណុះគ្រាប់ពូជ)

ចំពោះគ្រាប់កន្ទំថេតមុនយកទៅដាំត្រូវយកទៅខាត់សំបកអោយស្តើងដោយក្រដាសខាត់ទើបគ្រាប់ដុះបានល្អ ( ត្រូវខាត់អោយបានល្អមុនពេលយកទៅបណ្តុះ) ។

**ង,ការសាបព្រោះ :**

ត្រូវកប់គ្រាប់ពូជទៅក្នុងដី ជំរៅ ១-២ សម ក្នុងបរិមាណគ្រាប់ពូជ ៤00គ្រាប់ ក្នុងដី ១ម៉ែត្រការ៉េ ។ កុំព្រោះគ្រាប់ គរ គ្នារី ផ្តុំគ្នា នាំអោយកូនកន្ទំថេតដុះមកស្គម ។

**ច,ការថែរក្សា :**

ត្រូវស្រោចទឹកអោយបានទៀងទាត់ យកចិត្តទុកដាក់ ដកស្មៅចង្រៃក្នុងថ្នាល និង ដាក់លាមកសត្វបន្ថែម ។

**ឆ,ការដកកូនកន្ទំថេត :**

- ជៀសវាងការដាច់ឫស ត្រូវជីកដីអោយជ្រៅកុំអោយដាច់ឫសកែវ
- កូនកន្ទំថេតត្រូវដកថ្នមៗ ហើយរលាស់ដីចេញ និង បូលស្លឹកចោលអោយអស់មុនពេលដាំ ចងកូនកន្ទំថេតជាបាច់ ត្រូវគ្របឫសដោយការ៉ុងរឺ បាវសើមបើត្រូវដឹកជញ្ជូនផ្លូវឆ្ងាយ ។

**ជ,ការដាំ**

- ប្រមាណ៣ ខែក្រោយពេលបណ្តុះកូនកន្ទំថេតបានកំពស់ ១-១,៥ ម ដែលត្រូវពេលរៀបចំដីដាំ ។ ការដកដាំ ត្រូវប្រព្រឹត្តិទៅនៅពេលដីមានសំណើម ( រដូវវស្សា) ។
- ត្រូវជីករណ្តៅអោយបាន ជំរៅ 0,៥0ម ដើម្បីអោយកូនកន្ទំថេតដុះលូតលាស់បានល្អ ។
- មាត់រណ្តៅប្រវែង 0,២0ម ។
- ការដាំបើឫសកែវវែងពេកត្រូវកាត់វាចេញ ខ្លះ ហាមបត់ឫសក្នុងរណ្តៅនៅពេលដាំ ។ ត្រូវយកដី ពីថ្នាលបណ្តុះដាក់បាតរណ្តៅ រួចដាក់កូនកន្ទំថេតដោយកប់អោយត្រឹមស្មាមគល់ទើបង្ហាប់ និង ស្រោចទឹកជាស្រេច ។
- ការដាំជារបង ត្រូវដាំ ចន្លោះ ពីមួយដើម ទៅមួយដើម 0,៧0 ម-១

<u>រូបភាពការ ជីករណ្តៅ និង ការដាំកូនកន្ទំថេត</u>

### ឈ,ការផ្តល់ស្លឹកកន្ទុំថេតអោយ គោ_ក្របី ស៊ី

- ស្លឹកកន្ទុំថេតមានប្រូតេអ៊ីនខ្ពស់ ២២-២៥% ប្រើប្រាស់ធ្វើជាចំណីគោ-ក្របី ក៏ប៉ុន្តែត្រូវលាយជាមួយ ចំបើង ដែលមិនត្រូវអោយលើស ពី ២០-៣០%នៃទំងន់ចំបើង ដើម្បីចៀសវាង ការពុលដោយ សារជាតិអាស៊ីត និង សារជាតិដែលក្លិនក្រពុល ដែលមាននៅលើស្លឹកស្រស់ យើងត្រូវហាល ស្លឹកកន្ទុំថេត អោយ ស្រពាប់ជាមុនសិន មុន និង ផ្តល់អោយសត្វស៊ី ។

### ញ,របៀបកាត់ :

- ក្រោយពេលដាំរយះពេល ៣- ៤ ខែ បើសិនកន្ទុំថេតលូតលាស់ល្អ កំពស់ ពី ១,២០ ម-១,៥០ម កុំទុកខ្ពស់ពេកព្រោះពិបាកប្រមូលផល នៅពេលកាត់ធ្វើអោយកន្ទុំថេតបែកមែក និង ផ្តល់ទិន្នផលខ្ពស់ ។
- ការកាត់ត្រូវកាត់ដើម និង មែកអោយបានត្រឹមត្រូវ ងាយស្រួលអោយការលូតលាស់មែកសាខា និង ធ្វើអោយមានការលូតលាស់ស្លឹកច្រើន ។
- ក្រោយពេលកាត់ស្លឹកលើកទីមួយ ហើយមានរយះពេល ៦ អាទិត្យកាត់បានម្តងទៀតធ្វើរបៀបនេះបន្តរហូត ១ឆ្នាំ អាចកាត់បានពី ៦-៧ដង ។

### ដ,ការទុកពូជ :

- ចំពោះដើមកន្ទុំថេតពេលដែលត្រូវទុកធ្វើពូជត្រូវទុកអោយលូតលាស់ ធម្មតាមិនត្រូវកាត់ដើមចោលឡើយ
- នៅពេលផ្លែទុំត្រូវបេះយកមកប្រឡេះគ្រាប់ ហើយហាលថ្ងៃ អោយស្ងួត ល្អទុកសំរាប់ធ្វើ ពូជបន្តនៅ ឆ្នាំក្រោយៗបន្ថែមទៀត ។

## ២,៣,ស្នោគោក (Gliricidia)

### ក,ផលប្រយោជន៍

- ស្នោគោកអាចដុំនៅលើដីច្រើនប្រភេទ ទោះបីដីនោះខ្វះជីជាតិឬក៏ដីអាស៊ីតក៏ដោយ ។
- ស្នោគោកជាប្រភេទរុក្ខជាតិដែលធន់ទ្រាំនឹងភាពរាំងស្ងួត ។
- ជារុក្ខជាតិមិនធន់នឹងទឹកជោរជន់ ។
- ប្រើប្រាស់ធ្វើជាចំណីសត្វ ( សត្វទំពារអៀង)
- ត្រូវប្រើប្រាស់ពី២០-៣០% លាយជាមួយចំណីផ្សេងទៀតអោយសត្វស៊ី ជាពិសេសត្រូវហាល អោយស្រពាប់ សិន ។
- ដើមស្នោគោកប្រើសំរាប់ធ្វើឧស ។
- ក្រៅពីធ្វើចំណីសត្វ ស្លឹករបស់វាប្រើប្រាស់សំរាប់ធ្វើថ្នាំសំលាប់សត្វល្អិតធម្មជាតិ ។
- គេដាំវានៅតាមព្រំផ្ទះនិងជុំវិញសួនបន្លែធ្វើជារបងរស់ដើម្បីបន្លាចសត្វល្អិតកុំអោយប៉ះពាល់ដំណាំ ( ស្លឹកស្នោគោកបំភាយក្លិន-

- ចំពោះស្លឹកស្ងួតគេប្រើសំរាប់បណ្តេញសត្វល្អិតកុំអោយយាយីគ្រាប់ ពូជឬផលិតផលស្រូវ ។
- ការប្រើប្រាស់ស្លឹកស្ពោតោកធ្វើជាចំណីគោនិងក្របីជួយកាត់បន្ថយបរិមាណពពួកប្រូតូសេអ៊ែរ នៅក្នុងក្រពះដែលជួយ បង្កើនតួនាទីពពួកប៉ារ៉ាស៊ីត អោយសំយោគសារធាតុចិញ្ចឹមសំរាប់ខ្លួនសត្វ បានគ្រប់គ្រាន់ហើយធ្វើអោយសត្វធំធាត់ឆាប់ ។
- ចំពោះគោ-ក្របី គេទាមទារអោយមានការបង្ហាត់ស៊ីជាមុនសិន ដ៏រាបណាសត្វទាំងអស់នេះមានភាពសាំទៅនិងក្លិនស្លឹក ទើបគេអាចអោយវាស៊ីបន្តទៀតបាន ។ ការលាយចំរុះរវាងស្លឹក ជាមួយនិង ស្មៅចំណី សត្វផ្សេងៗទៀត ជាមធ្យោបាយមួយដ៏ល្អក្នុងការបង្ហាត់ សត្វអោយចេះស៊ីស្លឹកស្ពោគោគនេះ ។

## ខ.ការដាំដុះ

- ដាំពីមែកកាត់ ( ប្រវែងពី២០-៣០ សម) ហើយដាំនៅលើទួលមិនលិចទឹក ។
- ដាំរាងបញ្ឈិត ប្រសើរជាងដាំដោតត្រង់ចាក់ចូលទៅក្នុងដី ។
- ដើម្បីអោយមែកកាត់ងាយដុះ( ចាប់ឫស) ត្រូវសកសំបកនៅគល់ចេញប្រវែង៥-១០សម តែមិនត្រូវអោយប៉ះពាល់ដល់កោសិការុក្ខជាតិទេ ។
- កាដាំច្រើនធ្វើនៅរដូវភ្លៀង ឬ នៅខែណាដែលមានសំណើមខ្ពស់ ។
- ការដាំចន្លោះពីគុម្ពមួយទៅគុម្ពមួយពី១-២ម វាអាស្រ័យទៅនិងប្រភេទដី ។



រូបភាព ការដាំស្ពោគោគ

## គ.ការប្រមូលផល

- គ្រាវដើមឬកាត់មែកយកស្លឹកធ្វើជាចំណីសត្វ ។
- ដោយសារស្ពោគោកជារុក្ខជាតិងាយលូតលាស់និងមិនរើសប្រភេទដីគេអាចប្រមូលផលវាចាប់ពីវាមានអាយុពី ចន្លោះ៨-១២ សប្តាហ៍ឡើងទៅ ។

## ២,៤,ស្មៅដីរ (King Grass)

- ជាស្មៅដែលមានដើមដងខ្ពស់ៗងាយស្រួលច្រូតកាត់ និង ដឹកជញ្ជូន
- ជាប្រភេទស្មៅផ្តល់ទិន្នផលខ្ពស់ណាស់បើគេដាំនៅលើដីដែលមានជីជាតិខ្ពស់ និង មានការស្រោចស្រព
- ជាស្មៅដែលជាចំណីមានគុណភាពខ្ពស់
- ត្រូវច្រូតកាត់វាអោយបានញឹកញាប់ ដើម្បីរក្សាអោយមានស្លឹកច្រើន -កាត់រវៀងរាល់ ៤-៦ សប្តាហ៍
- បើចង់អោយ វាដុះលូតលាស់ល្អគេត្រូវប្រើប្រាស់ជីធម្មជាតិបន្ថែម
- មិនសមស្របទៅនិង តំបន់ដែលមានរដូវប្រាំងវែង

## ២,៥,ការដាំស្មៅ ដីរ

- ដាំដោយកាត់ដើម ជាកំណាត់ ៨០ សម x ៨០ សម
- ចន្លោះ ពី ១គុម្ព ទៅ ១ គុម្ព = ០,៥០ម
- រណ្តៅ ទំហំ ០,៣០ម x ០,៣០ម x ០,៣០ម x ០,៣០ម x ជំរៅ ០,២០
- បើចង់អោយវាលូតលាស់ល្អត្រូវប្រើប្រាស់ជីធម្មជាតិបន្ថែម



រូបភាពការដាំស្មៅដីរ

## ២,៦,ការផ្តល់អោយសត្វស៊ី

- ត្រូវច្រូតកាត់វាអោយបានញឹកញាប់ ដើម្បីរក្សាអោយមានស្លឹកច្រើន -កាត់រវៀងរាល់ ៤-៦ សប្តាហ៍
- អាចអោយគោ ស៊ីស្រស់បន្ថែម ជាមួយស្មៅ ។

## V.តារាងតាមដាន ការចិញ្ចឹមគោ ~ក្របី (ការលូតលាស់ របស់គោ~ក្របី)

| លរ | ប្រភេទសត្វ | ថ្ងៃ ខែ ចាប់ផ្តើម ចិញ្ចឹម | ឈ្មោះពូជ | ភេទ | ទំងន់ចាប់ផ្តើម (គក្រ) | ថ្ងៃខែ ឆ្នាំ | | ទំងន់ចុងឆ្នាំ (គក្រ) | ចំនួនកូនដែលកើតក្នុងចន្លោះពេលតាមដាន | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | ចាក់វ៉ាក់សាំង | ទំលាក់ព្រូន | | ចំនួនសរុប | ចំនួនញី | ចំនួនឈ្មោល | |
| ១ | គោ (៤ក្បាល) | ១,២,០៤ | ១,ប្រាម៉ាន់<br>២,<br>៣,<br>៤,<br>៥,<br>៦, | ញី | ១០០ | **សារទឹក**<br>១,៤,០៤ | **២,៥,០៤** | ១៥០ | ១ | ១ | ០ | |
| ២ | ក្របី | | ១,<br>២,<br>៣,<br>៤,<br>៥,<br>៦, | | | | | | | | | |